ក្រុមប្រឹក្សាយុត្តិធម៌បរិស្ថាន

កិច្ចប្រជុំលើកទី 28

ថ្ងៃព្រហស្បតិ៍ ទី 8 ខែតុលា ឆ្នាំ 2026 ម៉ោង 6:30 ល្ងាច

ប្រជុំផ្ទាល់នៅ៖ Springfield MA

South Congregational Church

45 Maple Street, Springfield, MA


កិច្ចដំណើរការប្រជុំ និងរបៀបវារៈ

ក្រុមប្រឹក្សាយុត្តិធម៌បរិស្ថាន

កិច្ចប្រជុំលើកទី 28 • ថ្ងៃទី 8 ខែតុលា ឆ្នាំ 2026 • ម៉ោង 6:30 ល្ងាច

កិច្ចដំណើរការប្រជុំ

- **ការបកប្រែភាសានឹងត្រូវបានផ្តល់ជូនជាភាសា៖ Español, Kreyòl ayisyen, 普通话, Português, Kriolu និងTiếng Việt។**
  - ដើម្បីចូលរួមជាភាសាអង់គ្លេស សូមចុចលើរូបសញ្ញា “Interpretation” រួចជ្រើសយកភាសា English ។
  - Para entrar no canal em português, clique no ícone “Interpretation” e selecione “Portuguese”
  - Si alguien desea interpretación en español, haga clic en “Interpretation” y seleccione “Spanish”
  - Pa partisipa na Kriolu, klika na íkone "Intirpretason" y silisiona "Cape Verdean Creole”
  - Pou rantre nan chanèl kreyòl ayisyen an, klike sou ikòn “Interpretation” an epi chwazi “Haitian Creole”
  - 要以普通话参加会议，请单击口语图标并选择 "Chinese”.
  - Để vào kênh bằng tiếng Việt, hãy nhấp vào biểu tượng “Interpretation” và chọn “Vietnamese”.
- **សូមនិយាយយឺតៗ។**
- **អ្នកចូលរួមទាំងអស់ត្រូវតែជ្រើសរើសបណ្តាញភាសា ទោះបីជាមើលបទបង្ហាញនោះជាភាសាអង់គ្លេសក៏ដោយ។**



- **ប្រសិនបើអ្នកចង់បានស្នាយជាទម្រង់ឯកសារបកប្រែ សូមចូលទៅកាន់គេហទំព័រ EJC តាមរយៈ : https://www.mass.gov/service-details/environmental-justice-council-ejc-meetings**

កិច្ចប្រជុំនេះកំពុងត្រូវបានថតទុក

របៀបវារៈ៖

- ទិដ្ឋភាពទូទៅនៃកិច្ចប្រជុំ កិច្ចដំណើរការប្រជុំ និងរបៀបវារៈ
- ការហៅឈ្មោះសមាជិក និងការអនុម័តលើកំណត់ហេតុប្រជុំ EJC ពីមុន
- មតិយោបល់សាធារណៈ
- កម្មវិធីជំនួយគាំទ្រអ្នកធ្វើអន្តរាគមន៍
- មតិយោបល់សាធារណៈ (តាមពេលវេលាអនុញ្ញាត)
- ជំហានបន្ទាប់
- ការលើកវារកាល



ការអនុម័តលើកំណត់ហេតុប្រជុំថ្ងៃទី 13 ខែសីហា ឆ្នាំ 2026 និងការហៅឈ្មោះ៖ សមាជិកក្រុមប្រឹក្សា EJ

- Madeline Fraser Cook
- Melissa Harding-Ferretti
- Cheryll Holley
- Caroline Hon
- Lydia Lowe
- Marcos Luna
- Peter Maathey
- María Belén Power
- Sofia Owen
- Jen Salinetti
- Patricia Spence
- Miles Gresham
- Harleen Marwah
- Paula Garcia

សំណួរ និងមតិយោបល់សាធារណៈ

សូមកំណត់មតិយោបល់នីមួយៗត្រឹមរយៈពេលពីរនាទី ដើម្បីទុកពេលឱ្យអ្នកដទៃទៀតបញ្ចេញមតិ

កម្មវិធីជំនួយគាំទ្រអ្នកធ្វើអន្តរាគមន៍

ទិដ្ឋភាពទូទៅនៃកម្មវិធីផ្តល់ជំនួយគាំទ្រដល់អ្នកអន្តរាគមន៍

ក្រសួងសេវាសាធារណៈ: ផ្នែកចូលរួមរបស់សាធារណជន

ថ្ងៃទី 8 ខែតុលាឆ្នាំ 2026

ប្រធានបទដែលគ្របដណ្តប់នៅក្នុងបទបង្ហាញ៖

- គោលបំណងនៃកម្មវិធីផ្តល់ជំនួយគាំទ្រដល់អ្នកអន្តរាគមន៍
- ដំណើរការនីតិវិធីដែលមានសិទ្ធិទទួលបានការអន្តរាគមន៍
- សិទ្ធិ និងការទទួលខុសត្រូវរបស់អ្នកអន្តរាគមន៍
- ដំណើរការដើម្បីក្លាយជាអ្នកអន្តរាគមន៍
- ដំណើរការក្នុងការអន្តរាគមន៍ និងដំណើរការក្នុងការដាក់ពាក្យស្នើសុំជំនួយអន្តរាគមន៍ឥតសំណង
- អង្គភាពដែលមានសិទ្ធិទទួលបានមូលនិធិជំនួយឥតសំណង
- ព័ត៌មានដែលតម្រូវឱ្យមាននៅក្នុងពាក្យស្នើសុំជំនួយឥតសំណង
- ដំណើរការផ្តល់ជំនួយឥតសំណង និងការទូទាត់ប្រាក់
- ការប្រើប្រាស់មូលនិធិជំនួយឥតសំណង
- ប្រព័ន្ធគ្រប់គ្រងជំនួយឥតសំណង (GMS) - ផតថលដាក់ពាក្យសុំជំនួយឥតសំណងតាមអនឡាញ
- ធនធានដែលមាន

គោលបំណងនៃកម្មវិធីផ្តល់ជំនួយគាំទ្រដល់អ្នកអន្តរាគមន៍ (“កម្មវិធី”)



- ផ្តល់មូលនិធិដល់ក្រុមដែលមានសិទ្ធិ ដែលមិនអាចចូលរួមក្នុងនីតិវិធីរបស់ក្រសួងសេវាសាធារណៈ (“DPU” ឬ “ក្រសួង”) ឬក្រុមប្រឹក្សាកំណត់ទីតាំងបរិក្ខារថាមពល (“ក្រុមប្រឹក្សាកំណត់ទីតាំង”) ដោយសារការលំបាកផ្នែកហិរញ្ញវត្ថុ
- អនុញ្ញាតឱ្យអ្នកទទួលជំនួយរ៉ាប់រងថ្លៃសេវាសម្រាប់មេធាវី សាក្សីជំនាញ អ្នកជំនាញសហគមន៍ ការចំណាយផ្នែករដ្ឋបាល និងការចំណាយដែលមានសិទ្ធិផ្សេងទៀត
- ផ្តល់ឱ្យសំឡេងចម្រុះនូវសិទ្ធិចូលរួម និងឱកាសក្នុងការជះឥទ្ធិពលលើការសម្រេចចិត្ត
- គ្រប់គ្រងដោយផ្នែកការចូលរួមរបស់សាធារណជន (DPP) នៃក្រសួង

ការផ្តល់មូលនិធិមានសម្រាប់ដំណើរការនីតិវិធីដែលបានចាប់ផ្តើមនៅថ្ងៃទី 1ខែកក្កដា ឆ្នាំ 2026 ឬបន្ទាប់ពីថ្ងៃនេះ

ដំណើរការនីតិវិធីដែលអាចទទួលបានមូលនិធិជំនួយឥតសំណងសម្រាប់ការអន្តរាគមន៍

ផ្នែកការងារ

- ញត្តិពីក្រុមហ៊ុនសេវាសាធារណៈ សុំផ្លាស់ប្តូរអត្រាថ្លៃចែកចាយអគ្គិសនី និងឧស្ម័នសម្រាប់អតិថិជន
- ផែនការទំនើបកម្មបណ្តាញអគ្គិសនី និងការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ
- ញត្តិស្តីពីការរាស់វែងថាមពលសុទ្ធ និងការភ្ជាប់បណ្តាញ (ឧ. ការយល់ព្រមលើស្តង់ដាភ្ជាប់បណ្តាញដែលបានកែសម្រួល)
- កម្មវិធីប្រសិទ្ធភាពថាមពល និងការកាត់បន្ថយការបំភាយឧស្ម័នកាបូន (ឧ. កម្មវិធីសាកល្បងសម្រាប់ថាមពលកម្តៅក្រោមដីដែលភ្ជាប់ជាបណ្តាញ អត្រាថ្លៃម៉ាស៊ីនបូមកម្តៅ)

ក្រុមប្រឹក្សាកំណត់ទីតាំង

ពិនិត្យមើលសំណង់ហេដ្ឋារចនាសម្ព័ន្ធថាមពលធំៗដែលបានស្នើឡើង

- ស្ថានីយផលិតថាមពលកកើតឡើងវិញ (ថាមពលពន្លឺព្រះអាទិត្យ, ថាមពលខ្យល់)
- ស្ថានីយស្តុកថាមពលថ្ម
- ស្ថានីយ៍រង
- ហេដ្ឋារចនាសម្ព័ន្ធបញ្ជូន និងចែកចាយ
- បំពង់បង្ហូរឧស្ម័ន និងគ្រឿងបរិក្ខារដែលពាក់ព័ន្ធ

ការស៊ើបអង្កេត និងការបង្កើតបទប្បញ្ញត្តិដែលផ្តួចផ្តើមដោយក្រសួងមិនមានសិទ្ធិទទួលបានមូលនិធិជំនួយឥតសំណងនោះទេ។

សិទ្ធិ និងការទទួលខុសត្រូវរបស់អ្នកអន្តរាគមន៍

ការបង្កើនកម្រិតនៃការចូលរួមក្នុងដំណើរការនីតិវិធី

អ្នកអន្តរាគមន៍

អ្នកចូលរួមមានកំណត់

អ្នកបញ្ចេញមតិជាសាធារណៈ

អ្នកអន្តរាគមន៍ គឺជាអ្នកចូលរួម (ភាគី) ដែលត្រូវបានទទួលស្គាល់ស្របច្បាប់ ដែលមានកម្រិតនៃការចូលរួមខ្ពស់ជាងនៅក្នុងដំណើរការនីតិវិធី

- បញ្ជូនភស្តុតាង
- ចេញសំណើព័ត៌មាន
- បង្ហាញ និងសាកសួរឆ្លងសាក្សី
- ឯកសារសង្ខេប
- ការសម្រេចចិត្តលើបណ្តឹងឧទ្ធរណ៍


- ការធ្វើជាអ្នកអន្តរាគមន៍តម្រូវឱ្យមានពេលវេលា ថាមពល និងធនធាន

អ្នកចូលរួមមានកំណត់

បុគ្គល ឬអង្គភាពដែលការចូលរួមរបស់ពួកគេត្រូវបានដាក់កម្រិតចំពោះបញ្ហាជាក់លាក់នៅក្នុងដំណើរការនីតិវិធី។ អាចដាក់មតិយោបល់ ដាក់សេចក្តីសង្ខេប និងទទួលបានច្បាប់ចម្លងនៃសំណើព័ត៌មាន និងការឆ្លើយតប ការឆ្លើយតបចំពោះសំណើព័ត៌មាន និងសក្ខីកម្ម។

អ្នកបញ្ចេញមតិជាសាធារណៈ

ផ្តល់មតិត្រឡប់ជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់អំពីដំណើរការនីតិវិធី ប៉ុន្តែមិនមានសិទ្ធិជាអ្នកអន្តរាគមន៍នោះទេ



- ញត្តិសុំធ្វើអន្តរាគមន៍ត្រូវតែរួមបញ្ចូលព័ត៌មានមូលដ្ឋានអំពីអ្នកដាក់ញត្តិ (ឈ្មោះ អាសយដ្ឋាន និងព័ត៌មានទំនាក់ទំនង) របៀបដែលអ្នកដាក់ញត្តិត្រូវបានរងផលប៉ះពាល់យ៉ាងខ្លាំង និងជាក់លាក់ដោយដំណើរការនីតិវិធី និងបញ្ហាអ្វីខ្លះដែលពួកគេនឹងដោះស្រាយក្នុងនាមជាអ្នកអន្តរាគមន៍
- ពេលវេលាដើម្បីដាក់ញត្តិសុំធ្វើអន្តរាគមន៍
  - ក្រសួង - ជាធម្មតា 7 ថ្ងៃមុនពេលសវនាការស្តាប់យោបល់សាធារណៈ
  - ក្រុមប្រឹក្សាកំណត់ទីតាំង - ជាធម្មតា 14 ថ្ងៃបន្ទាប់ពីសវនាការសាធារណៈ
  - អាចស្នើសុំពេលវេលាបន្ថែមដើម្បីដាក់ញត្តិសុំធ្វើអន្តរាគមន៍ ប្រសិនបើធ្វើមុនកាលកំណត់ដើម

*សេចក្តីជូនដំណឹងត្រូវបានគេហៅថា សេចក្តីជូនដំណឹងអំពីការដាក់ពាក្យស្នើសុំ និងសវនាការសាធារណៈនៅក្នុងដំណើរការនីតិវិធីរបស់ក្រសួង ឬសេចក្តីជូនដំណឹងអំពីការវិនិច្ឆ័យ និងសវនាការសាធារណៈនៅក្នុងដំណើរការនីតិវិធីរបស់ក្រុមប្រឹក្សាកំណត់ទីតាំង

ដំណើរការក្នុងការអន្តរាគមន៍ និងដំណើរការក្នុងការដាក់ពាក្យស្នើសុំជំនួយអន្តរាគមន៍ឥតសំណង

ដំណើរការដើម្បីធ្វើអន្តរាគមន៍ក្នុងដំណើរការនីតិវិធី

ក្រសួង ឬក្រុមប្រឹក្សាកំណត់ទីតាំងចេញសេចក្តីជូនដំណឹងអំពីដំណើរការ

អនាគតអ្នកអន្តរាគមន៍ដាក់ញត្តិសុំធ្វើអន្តរាគមន៍

DPU ឬក្រុមប្រឹក្សាទីតាំងសម្រេចលើញត្តិសុំធ្វើអន្តរាគមន៍

ឋាន:ជាអ្នកអន្តរាគមន៍ត្រូវបានផ្តល់ជូនឬបដិសេធ

ការទទួលបានឋាន:ជាអ្នកអន្តរាគមន៍គឺជាលក្ខខណ្ឌតម្រូវជាមុន ដើម្បីទទួលបានមូលនិធិតាមរយៈកម្មវិធី

ដំណើរការដើម្បីដាក់ពាក្យសុំជំនួយឥតសំណងសម្រាប់អ្នកអន្តរាគមន៍

បេក្ខជនស្នើសុំជំនួយឥតសំណងបង្កើតគណនី MyMassGov និងប្រូហ្វាល

បេក្ខជនស្នើសុំជំនួយឥតសំណងដាក់ពាក្យស្នើសុំត្រឹមថ្ងៃផុតកំណត់ដើម្បីធ្វើអន្តរាគមន៍

DPP ពិនិត្យមើលពាក្យស្នើសុំភាពពេញលេញក្នុងរយៈពេល 10 ថ្ងៃធ្វើការ

DPP ពិនិត្យមើលពាក្យស្នើសុំ និងចេញសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរក្នុងរយៈពេល 30 ថ្ងៃ

ការផ្តល់ជូនក្រោមលក្ខខណ្ឌ ប្រសិនបើការសម្រេចលើញត្តិស្នើសុំធ្វើអន្តរាគមន៍មិនត្រូវបានចេញទេ

ដាក់បញ្ចូនសំណើទូទាត់ប្រាក់ជំនួយ នៅពេលដែលជំនួយត្រូវបានយល់ព្រម និងទទួលបានឋាន:ជាអ្នកអន្តរាគមន៍

បញ្ជូនរបាយការណ៍ចុងក្រោយក្នុងរយៈពេល 30 ថ្ងៃបន្ទាប់ពីការបញ្ចប់ដំណើរការនីតិវិធី

អង្គភាពដែលមានសិទ្ធិទទួលបានមូលនិធិជំនួយឥតសំណង

មានតែភាគីដែលទទួលបានហាន:ជាអ្នកអន្តរាគមន៍ប៉ុណ្ណោះ ដែលមានសិទ្ធិទទួលបានមូលនិធិជំនួយឥតសំណង

អង្គភាពដែលមិនមានសិទ្ធិរួមមាន បុគ្គល អ្នកចូលរួមមានកំណត់ និងអ្នកដែលញត្តិសុំអន្តរាគមន៍របស់ពួកគេមិនទទួលបានជោគជ័យ

- ✓ អង្គការដែលតំណាងឱ្យអតិថិជនតាមលំនៅឋាន ប្រជាពលរដ្ឋដែលមានប្រាក់ចំណូលទាប ឬមធ្យម ប្រជាពលរដ្ឋដែលរស់នៅក្នុងសហគមន៍ដែលរងការធើសអើងជាប្រវត្តិសាស្ត្រ ឬមានបន្ទុកធ្ងន់ និងមិនស្ថិតទទួលបានសេវា ឬប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់ដែលមានបន្ទុកធ្ងន់
- ✓ ស្ថាប័នរដ្ឋាភិបាល (ទីក្រុង ទីប្រជុំជន ស្រុក មណ្ឌលសិក្សាធិការតំបន់ ឬខោនធី)
- ✓ ទីភ្នាក់ងារៀបចំផែនការថ្នាក់តំបន់ ឧ. ក្រុមប្រឹក្សាៀបចំផែនការតំបន់មេត្រូប៉ូលីតង់ គណៈកម្មការ Cape Cod
- ✓ កុលសម្ព័ន្ធដែលត្រូវបានទទួលស្គាល់ដោយសហព័ន្ធ ត្រូវបានទទួលស្គាល់ដោយរដ្ឋ ឬត្រូវបានដឹងឮដោយរដ្ឋ
- ✓ ក្រុមដែលមានសមាជិកបីនាក់ ឬច្រើននាក់ (“សមាគមដែលមិនបានចុះបញ្ជី”) ហើយដែលអាចរងផលប៉ះពាល់ជាក់លាក់ និងយ៉ាងខ្លាំងពីនីតិវិធី

ព័ត៌មានដែលតម្រូវឱ្យមាននៅក្នុងពាក្យស្នើសុំជំនួយឥតសំណង

ពាក្យស្នើសុំជំនួយគួរតែ

- បង្ហាញពីការលំបាកផ្នែកហិរញ្ញវត្ថុយ៉ាងខ្លាំង (អសមត្ថភាពក្នុងការចូលរួមដោយមិនទទួលបានជំនួយឥតសំណង)
- ផ្តល់ព័ត៌មានអំពីដំណើរការនីតិវិធីចុងក្រោយចំនួន 3 ដែលអ្នកដាក់ពាក្យស្នើសុំបានធ្វើអន្តរាគមន៍ប្រសិនបើមាន
- ពិពណ៌នាអំពីគោលដំហរ និងផលប្រយោជន៍របស់អ្នកដាក់ពាក្យស្នើសុំនៅក្នុងដំណើរការនីតិវិធី
- ពិពណ៌នាអំពីផែនការដែលបានបញ្ជាក់យ៉ាងច្បាស់ សមហេតុផល និងអាចសម្រេចបានសម្រាប់ការចូលរួមក្នុងនីតិវិធី រួមទាំងការរួមចំណែកដែលរំពឹងទុកចំពោះកំណត់ត្រាភស្តុតាង
- ពិពណ៌នាអំពីទស្សន:ពិសេសរបស់អ្នកដាក់ពាក្យសុំ

ឯកសារដែលត្រូវដាក់បញ្ចូនជាមួយពាក្យសុំ

ថវិកាដែលបានស្នើតាមចំណុចនីមួយៗ

ទម្រង់ព័ត៌មានអំពីមេធាវី និងអ្នកជំនាញ

ទម្រង់បែបបទផ្ទេរមូលនិធិតាមប្រព័ន្ធអេឡិចត្រូនិក (EFT)

ទម្រង់បែបបទ W-9 ដែលមាន TIN (EIN ឬ SSN)

ទម្រង់បែបបទលេខ 990

ការផ្តល់ជំនួយ និងការទូទាត់ប្រាក់

ចំនួនទឹកប្រាក់រង្វាន់

- រហូតដល់ $150,000 ក្នុងអ្នកទទួលជំនួយម្នាក់
- រហូតដល់ $500,000 សម្រាប់អ្នកទទួលជំនួយទាំងអស់នៅក្នុងដំណើរការនីតិវិធី

ជម្រើសទូទាត់ប្រាក់

អ្នកទទួលជំនួយជ្រើសរើសទទួលជំនួយឥតសំណងជាជម្រើសណាមួយដូចខាងក្រោម៖

a) ការទូទាត់ប្រាក់ជាមុន (ការបើកប្រាក់ជាដំណាក់កាលរហូតដល់ 20% នៃជំនួយឥតសំណង)

— ការទូទាត់ប្រាក់ជាមុនត្រូវឱ្យបង្ហាញពីមូលហេតុសមស្រប និងការលំបាកផ្នែកហិរញ្ញវត្ថុយ៉ាងខ្លាំង

b) ការទូទាត់សំណងវិញបន្ទាប់ពីមានការចំណាយកើតឡើងពេញមួយដំណើរការនីតិវិធី

សំណើទូទាត់ប្រាក់គួរតែត្រូវបានដាក់ស្នើនៅក្នុង GMS ដោយមានឯកសារគាំទ្រ (ការប៉ាន់ប្រមាណ វិក្កយបត្រ ឬបង្កាន់ដៃទទួលប្រាក់)

- ការទូទាត់ប្រាក់ត្រូវបានធ្វើឡើងក្នុងរយៈពេល 30 ថ្ងៃបន្ទាប់ពីទទួលបានសំណើទូទាត់ប្រាក់

ការប្រើប្រាស់មូលនិធិជំនួយឥតសំណង

ការប្រើប្រាស់ដែលមានសិទ្ធិទទួលបាន

ថ្លៃចំណាយរដ្ឋបាលរហូតដល់ 10% នៃចំនួនទឹកប្រាក់នៃជំនួយឥតសំណង ឬច្រើនជាងនេះ ប្រសិនបើត្រូវបានអនុញ្ញាតដោយនាយក DPP

ថ្លៃសេវាមេធាវី

ថ្លៃសេវាសាក្សីជំនាញ រួមទាំងថ្លៃសេវាអ្នកជំនាញសហគមន៍*

ការប្រើប្រាស់ដែលមិនមានសិទ្ធិទទួលបាន

ការទិញ ឬជួលឧបករណ៍

ការឃោសនាផ្នែកនយោបាយ

ការផ្សាយពាណិជ្ជកម្ម/ការធ្វើទីផ្សារដើម្បីផ្សព្វផ្សាយទស្សន:របស់អ្នកទទួលជំនួយទាក់ទងនឹងដំណើរការនីតិវិធី


ថ្លៃចំណាយសម្រាប់ការប្តឹងឧទ្ធរណ៍ចំពោះសេចក្តីសម្រេចចុងក្រោយរបស់ DPU ឬ EFSB នៅក្នុងដំណើរការនីតិវិធី

ការប្រើប្រាស់ខុសច្បាប់ គ្មានសីលធម៌ ឬមិនត្រឹមត្រូវផ្សេងទៀត

*អ្នកជំនាញសហគមន៍៖ សមាជិកនៃសហគមន៍ដែលរងផលប៉ះពាល់ រួមទាំងប្រជាជនរស់នៅ ឬក្រុមសហគមន៍ ដែលមានចំណេះដឹង ឬបទពិសោធន៍ផ្ទាល់ខ្លួនដែលពាក់ព័ន្ធនឹងដំណើរការនីតិវិធី

ប្រព័ន្ធគ្រប់គ្រងជំនួយឥតសំណង (GMS) - អក្រង់ចូលប្រព័ន្ធ

អ្នកដាក់ពាក្យសុំនឹងត្រូវចុះឈ្មោះសម្រាប់គណនី MyMassGov ជាមុនសិនហើយរង់ចាំការយល់ព្រម (អាចចំណាយពេលរហូតដល់ 48 ម៉ោង)



ប្រព័ន្ធគ្រប់គ្រងជំនួយឥតសំណង (GMS) - ផតថលដាក់ពាក្យសុំតាមអនឡាញ

វីដេអូ និងការណែនាំជាលាយលក្ខណ៍អក្សរអំពីរបៀបប្រើប្រាស់ GMS នឹងមកដល់ក្នុងពេលឆាប់ៗនេះ



ធនធានដែលមានសម្រាប់អ្នកដាក់ពាក្យសុំ

- Intervenor Support Grant Program webpage - (mass.gov/IntervenorProgram)
- សេចក្តីណែនាំអំពីកម្មវិធីជំនួយឧបត្ថម្ភអ្នកអន្តរាគមន៍ (ថ្ងៃទី 1 ខែកក្កដា ឆ្នាំ 2026)
- ខិត្តប័ណ្ណ
  - ការយល់ដឹងអំពីជំហាននានាក្នុងដំណើរការនីតិវិធីវិនិច្ឆ័យរបស់ក្រសួង
  - ខិត្តប័ណ្ណស្តីពីការយល់ដឹងអំពីជំហាននានាក្នុងដំណើរការនីតិវិធីរបស់ក្រុមប្រឹក្សាកំណត់ទីតាំង (កំពុងបង្កើត)
  - ខិត្តប័ណ្ណស្តីពីទិដ្ឋភាពទូទៅនៃកម្មវិធីជំនួយឧបត្ថម្ភអ្នកអន្តរាគមន៍
  - ការក្លាយជាអ្នកអន្តរាគមន៍ និងការដាក់ពាក្យសុំជំនួយ៖ ខិត្តប័ណ្ណព័ត៌មានទូទៅ
- ម៉ូឌុលវីដេអូ (កំពុងបង្កើត)
  - ទិដ្ឋភាពទូទៅនៃ DPU និងក្រុមប្រឹក្សាកំណត់ទីតាំង
  - ទិដ្ឋភាពទូទៅនៃកម្មវិធីជំនួយឧបត្ថម្ភអ្នកអន្តរាគមន៍
  - ការចូលរួមក្នុងនាមជាអ្នកអន្តរាគមន៍ - តួនាទី និងដំណើរការ
  - របៀបដាក់ពាក្យសុំជំនួយពីកម្មវិធីជំនួយឧបត្ថម្ភអ្នកអន្តរាគមន៍ក្នុង GMS (មានការថតអេក្រង់)
- សេចក្តីណែនាំអំពីប្រព័ន្ធគ្រប់គ្រងជំនួយឥតសំណង (កំពុងបង្កើត)
- អ៊ីមែលកម្មវិធី - dpu.isgp@mass.gov

សិក្ខាសាលាតាមប្រព័ន្ធអនឡាញនាពេលខាងមុខរបស់ក្រសួងសេវាសាធារណៈ

- **កម្មវិធីជំនួយឧបត្ថម្ភអ្នកអន្តរាគមន៍៖ ទិដ្ឋភាពទូទៅ និងរបៀបដាក់ពាក្យស្នើសុំ**

  ថ្ងៃទី 29 ខែតុលា ម៉ោង 1:00 - 2:00 រសៀល

- **ការស្វែងយល់អំពីតម្រូវការមុនពេលដាក់ពាក្យស្នើសុំសម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធថាមពលស្អាតទ្រង់ទ្រាយធំ**

  ថ្ងៃទី 12 ខែវិច្ឆិកា ម៉ោង 11:00 ព្រឹក - 12:00 ថ្ងៃត្រង់

- **ការក្លាយជាអ្នកអន្តរាគមន៍៖ ការយល់ដឹងអំពីដំណើរការ និងការដាក់ពាក្យសុំជំនួយពីកម្មវិធីជំនួយឧបត្ថម្ភអ្នកអន្តរាគមន៍**

  ថ្ងៃទី 3 ខែធ្នូ ម៉ោង 12:00 - 1:30 រសៀល

សំណួរ និងចម្ងើយ

សំណួរ និងមតិយោបល់សាធារណៈ

សូមកំណត់មតិយោបល់នីមួយៗត្រឹមរយៈពេលពីរនាទី
ដើម្បីទុកពេលឱ្យអ្នកដទៃទៀតបញ្ចេញមតិ



ជំហានបន្ទាប់ និងការលើកវារកាល

កាលបរិច្ឆេទប្រជុំបន្ទាប់៖

- ថ្ងៃទី 10 ខែធ្នូ

ព័ត៌មានអំពី EJC និងទីតាំងប្រជុំអាចរកឃើញនៅក្នុងតំណ

https://www.mass.gov/orgs/environmental-justice-council-ejc

ត្រូវស្នើសុំការបកប្រែផ្ទាល់នៃភាសាសញ្ញា ASL បីសប្តាហ៍មុនការប្រជុំតាមអ៊ីមែល

meetings@erg.com